# សេចក្តីថ្លែងការណ៍រួម
# ក្នុងឱកាសយុទ្ធនាការ១៦ថ្ងៃខួបទី៣០
# ក្រោមប្រធានបទ "ពិភពលោកពណ៌ទឹកក្រូចៈ បញ្ឈប់អំពើហិង្សាលើស្ត្រី និង ក្មេងស្រីចាប់ពីពេលនេះ"

ក្នុងនាមស្ថាប័នដែលជាតំណាងសហជីពនិងអង្គការសង្គមស៊ីវិលដែលកំពុងធ្វើការរួមចំណែកលើកកម្ពស់សមភាពយេនឌ័រនិងសិទ្ធិការងារនៅកម្ពុជា ចំនួន៤៧ ដែលមានរាយនាមខាងក្រោម យើងខ្ញុំសូមកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ជាពិសេស តាមរយៈក្រសួងកិច្ចការនារីដែលបានដឹកនាំកិច្ចការងារលើកកម្ពស់សិទ្ធិ និងស្ថានភាពរស់នៅរបស់ស្ត្រី។ ក្នុងនោះ រួមមានការតាំងចិត្តធ្វើឱ្យប្រសើរឡើងនូវគោលនយោបាយ និងច្បាប់ជាតិនានាជាពិសេស ផែនការធ្វើវិសោធនកម្មច្បាប់ស្តីពីការទប់ស្កាត់អំពើហិង្សាក្នុងគ្រួសារនិងកិច្ចការពារជនរងគ្រោះ ដែលយើងខ្ញុំសង្ឃឹមថាក្រសួងកិច្ចការនារីនឹងពន្លឿនដំណើរការធ្វើវិសោធនកម្មច្បាប់នេះអោយបានឆាប់រហ័សនិងមានប្រសិទ្ធិភាព ដើម្បីជាប្រយោជន៍ការពារសិទ្ធិស្ត្រី និងឱ្យស្របតាមបទដ្ឋានច្បាប់អន្តរជាតិដែលកម្ពុជាបានប្តេជ្ញាចិត្តក្នុងការអនុវត្ត។ ទោះយ៉ាងណា យើងសង្កេតឃើញថាករណីអំពើហិង្សានិងការបៀតបៀនផ្លូវភេទលើស្ត្រីនិងក្មេងស្រីបន្តកើតមានជារៀងរាល់ថ្ងៃ ទាំងនៅក្នុងផ្ទះ នៅតាមដងផ្លូវ សាលារៀន និងកន្លែងការងារដែលធ្វើឱ្យប៉ះពាល់ដល់សិទ្ធិសេរីភាពជាមូលដ្ឋានរបស់ស្ត្រី។

ក្នុងវិស័យការងារ កន្លងមកមានរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើងនិងកាបូបមួយចំនួនបានកំណត់វិធានផ្ទៃក្នុង មិនឱ្យមានការប្រើហិង្សាក្នុងកន្លែងការងារក៏ពិតមែន ប៉ុន្តែតាមរបាយការណ៍របស់អង្គការឃែរកម្ពុជាឆ្នាំ២០១៧ និងរបាយការណ៍របស់មជ្ឈមណ្ឌលសាមគ្គីភាពឆ្នាំ២០១៨ កម្មការនីយ៉ាងហោចម្នាក់ក្នុងចំណោម៣នាក់ បានរាយការណ៍ថា ពួកគាត់រងនូវអំពើហិង្សានិងការបៀតបៀនពីសំណាក់អ្នកគ្រប់គ្រង និងអ្នករួមការងារជាមួយ។ ស្ថានភាពនៃអំពើហិង្សានិងការបៀតបៀននៅក្នុងពិភពការងារ រឹតតែធ្ងន់ធ្ងរចំពោះកម្មការនីក្នុងវិស័យសេវាកម្សាន្ត ទេសចរណ៍ សិល្បៈ រហូតដល់វិស័យសារព័ត៌មាន។ ទន្ទឹមនឹងនេះផងដែរ ផ្នត់គំនិតសង្គមដែលមានលក្ខណៈរើសអើងទៅលើស្ត្រី ប្រភេទការងាររបស់ស្ត្រី និងវប្បធម៌នៃការបន្ទោសស្ត្រីរងគ្រោះនៅតែបន្តកើតមានពីសំណាក់មន្ត្រីអ្នកផ្តល់សេវាផ្លូវច្បាប់ និងសេវាពាក់ព័ន្ធនានា។ ជាញឹកញាប់នៅពេលដែលស្ត្រីរងគ្រោះរាយការណ៍ករណីរបស់ខ្លួនអាជ្ញាធរមួយចំនួនបែរជាបន្ទោសថា ករណីនោះមិនបានមកប្តឹងភ្លាមបន្ទាប់ពីកើតហេតុ ខណៈអាជ្ញាយុកាលនៃការប្តឹងនៅមិនទាន់ផុតនៅឡើយ។ មានករណីខ្លះ អាជ្ញាធរបានបំភ័យស្ត្រីរងគ្រោះឱ្យបោះបង់ចោលនូវការដាក់ពាក្យបណ្តឹងព្រហ្មទណ្ឌទៅវិញ តាមរយៈការបន្លាចស្ត្រីរងគ្រោះអំពីកាតព្វកិច្ចធ្វើគ្រាប់

ឡើងវិញ ឬការផ្តល់ព័ត៌មានទៅដល់ក្រុមគ្រួសារ ឬអាជ្ញាធរភូមិឃុំ ដែលនឹងធ្វើឱ្យបែកការសម្ងាត់របស់ស្ត្រីជាដើម។ ទង្វើទាំងនេះបានជះផលប៉ះពាល់អវិជ្ជមានជាខ្លាំងទៅលើស្ត្រីរងគ្រោះ ធ្វើឱ្យពួកគេបាក់ទឹកចិត្ត និងកាន់តែរងគ្រោះបន្ថែមទៀត។ កត្តាដែលលើកឡើងទាំងនេះក៏ជាហេតុផលដែលរារាំងស្ត្រីនិងក្មេងស្រីរងគ្រោះក្នុងការរាយការណ៍ពីករណីអំពើហិង្សាដែលខ្លួនជួបប្រទះផងដែរ ជាពិសេសសម្រាប់កម្មការនី ទាំងខ្លាចបាត់បង់ការងារផង ទាំងមិនមានទំនុកចិត្តលើប្រព័ន្ធយុត្តិធម៌ផង។

ក្នុងឱកាសដែលកម្ពុជាកំពុងចូលរួមប្រារព្ធយុទ្ធនាការ១៦ថ្ងៃដើម្បីលុបបំបាត់អំពើហិង្សាផ្អែកលើយេនឌ័រ ឆ្នាំ២០២១នេះ យើងខ្ញុំសូមធ្វើការស្នើសុំដល់ រាជរដ្ឋាភិបាលកម្ពុជា តាមរយៈសភាជាតិ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្រសួងកិច្ចការនារី ក្រសួងមហាផ្ទៃ អនុវត្តកាតព្វកិច្ចរបស់រដ្ឋទៅតាមសេចក្តីសង្កេតសន្និដ្ឋានចុងក្រោយរបស់គណៈកម្មាធិការទទួលបន្ទុកអនុសញ្ញា ស៊ីដ កាលពីឆ្នាំ ២០១៩ កថាខណ្ឌ ៣៧ (ឆ) ដោយផ្តល់សច្ចាប័នជាអាទិភាពទៅលើអនុសញ្ញា ១៨៣ ស្តីពីការការពារមាតុភាព អនុសញ្ញា ១៨៩ ស្តីពីការងារសមរម្យសម្រាប់កម្មករការងារតាមផ្ទះ អនុសញ្ញា ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សានិងការបៀតបៀននៅក្នុងពិភពការងារ ព្រមទាំងផ្តល់សច្ចាប័នលើអនុសញ្ញា ១៤៤ ស្តីពីការពិគ្រោះយោបល់ត្រីភាគីរវាងរដ្ឋ និយោជក និងកម្មករនិយោជិត ដើម្បីជាសក្ខីភាពបញ្ជាក់ពីការប្តេជ្ញាចិត្តយ៉ាងខ្ពង់ខ្ពស់របស់រាជរដ្ឋាភិបាលកម្ពុជាក្នុងការ **បញ្ឈប់អំពើហិង្សាលើស្ត្រីនិងក្មេងស្រីចាប់ពីពេលនេះ។**

### អនុសញ្ញា ១៩០ ស្តីពីការលុបបំបាត់អំពើហិង្សានិងការបៀតបៀននៅក្នុងពិភពការងារ (ឆ្នាំ២០១៩)

កម្ពុជានៅមិនទាន់មានយន្តការច្បាស់លាស់ក្នុងការរាយការណ៍និងដោះស្រាយករណីអំពើហិង្សាក្នុងពិភពការងារ និងអនុវត្តច្បាប់ឱ្យមានប្រសិទ្ធភាពក្នុងការការពារស្ត្រីរងគ្រោះដោយសារអំពើហិង្សានិងការបៀតបៀននៅឡើយទេ។ ច្បាប់នៅកម្ពុជាក៏មិនទាន់មាននិយមន័យច្បាស់លាស់ អំពីអំពើហិង្សានិងការបៀតបៀនផ្លូវភេទនៅក្នុងពិភពការងារ ដែលគ្របដណ្តប់ពិភពការងារដែលមានវិសាលភាពលើសពីកន្លែងការងារ ហើយដែលអាចផ្តល់ការការពារដល់កម្មករនិយោជិតគ្រប់រូប ដោយមិនប្រកាន់នូវប្រភេទការងារ ប្រភេទនៃកិច្ចសន្យាការងារ និងរួមបញ្ចូលទាំងពេលវេលា និងកន្លែងសម្រាកញ៉ាំអាហារ ពេលម៉ោងធ្វើដំណើរទៅធ្វើការឬចេញពីធ្វើការ ការប្រាស្រ័យទាក់ទងពាក់ព័ន្ធនឹងការងារ រួមទាំងការងារដែលធ្វើនៅតាមទីសាធារណៈ ឬ កន្លែងឯកជនដូចជាអ្នកលក់ដូរតាមដងផ្លូវ និងអ្នកធ្វើការតាមផ្ទះជាដើម។ ចំពោះជនប្រព្រឹត្ត ក្រមព្រហ្មទណ្ឌនៅកម្ពុជាបានចែងត្រឹមតែជាអ្នកគ្រប់គ្រងឬបុគ្គលមានអំណាចប៉ុណ្ណោះ ចំណែកអ្នករួមការងារ បុគ្គលិក ក្រោមឱវាទ និងអតិថិជនក៏គួររួមបញ្ចូលផងដែរ។

បុគ្គលគ្រប់រូបដែលប្រព្រឹត្តអំពើហិង្សាត្រូវតែទទួលខុសត្រូវចំពោះមុខច្បាប់ ហើយក៏គួរផ្ដល់នូវសេវាប្រឹក្សា និងវិធានការណ៍ផ្សេងៗដើម្បីទប់ស្កាត់កុំឱ្យជននោះប្រព្រឹត្តអំពើហិង្សានិងការបៀតបៀនបន្តទៀត។ ជាងនេះទៅទៀត ច្បាប់នៅកម្ពុជាក៏នៅមិនទាន់កំណត់នូវកាតព្វកិច្ចចាំបាច់របស់និយោជក ក្នុងការការពារកម្មករនិយោជិតពីអំពើហិង្សានិងការបៀតបៀនទាំងនៅកន្លែងការងារ រហូតដល់ការគិតគូរពីផលប៉ះពាល់នៃអំពើហិង្សាក្នុងគ្រួសារដល់កម្មករនិយោជិត និងមិនទាន់មានការធានាបានថាកម្មករនិយោជិតទទួលបាននូវដំណោះស្រាយប្រកបដោយយុត្តិធម៌គ្រប់ជ្រុងជ្រោយនៅឡើយ។ ក្នុងនោះ រួមមានដូចជា ការទទួលបាននូវសំណង សិទ្ធិក្នុងការចូលធ្វើការវិញ ការទទួលបាននូវសេវាព្យាបាលនិងប្រឹក្សាផ្លូវចិត្ត និងការកែប្រែគោលនយោបាយឬទំនៀមទម្លាប់អវិជ្ជមាននានា។ លើសពីនេះ យន្តការច្បាប់នៅកម្ពុជា ជាពិសេសទៅលើដំណើរការដោះស្រាយករណីព្រហ្មទណ្ឌពាក់ព័ន្ធនិងអំពើហិង្សាផ្លូវភេទ ក៏គួរតែមានការកែលម្អផងដែរ ដោយសារការអនុវត្តយន្តការនេះកន្លងមក បានធ្វើការទម្លាក់បន្ទុកក្នុងការប្ដឹងឬបន្តបណ្ដឹងព្រហ្មទណ្ឌ និងបន្ទុកក្នុងការបង្ហាញនូវភស្តុតាងទៅលើស្ត្រី និងក្មេងស្រីរងគ្រោះទៅវិញ ដែលនេះជាកត្តារារាំងយ៉ាងខ្លាំងដល់ស្ត្រីនិងក្មេងស្រីរងគ្រោះក្នុងរាយការណ៍ករណីរបស់ពួកគាត់។ ជារួម ស្ត្រីកម្មករនិយោជិត គ្រប់វិស័យ ត្រូវការចាំបាច់ណាស់នូវយន្តការនៃការរាយការណ៍និងដោះស្រាយករណីអំពើហិង្សា ដែលអាចធានាសុវត្ថិភាពការងាររបស់ពួកគាត់ ផ្ដល់នូវទំនុកចិត្ត និងការរក្សាការសម្ងាត់ពីអត្តសញ្ញាណរបស់ស្ត្រី។

**អនុសញ្ញា១៨៣ ស្ដីពីការការពារមាតុភាព (ឆ្នាំ២០០០)**

កន្លងមកនេះ យើងសង្កេតឃើញនៅក្នុងវិស័យកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូបមានភាពប្រសើរឡើង មួយចំនួន ដូចជាកម្មករមានផ្ទៃពោះមានសិទ្ធិចេញមុនម៉ោងសម្រាក ១០ឬ២០នាទី មានពេលសម្រាកក្នុងម៉ោងការងារ ទទួលបានជំនួយពីរាជរដ្ឋាភិបាល អត្ថប្រយោជន៍ពីរបបសន្តិសុខសង្គម (បសស) និងការសម្រាកមាតុភាព។ ដោយឡែកកម្មការនីនៅក្នុងវិស័យការងារក្រៅប្រព័ន្ធរួមមានខាងសំណង់ ឡូតដូ សេវាកម្សាន្ត ការងារតាមផ្ទះ ផ្នែកសេវាកម្មតាមក្រុមហ៊ុនសន្តិសុខជាដើម មិនត្រឹមតែមិនបានទទួលអត្ថប្រយោជន៍មាតុភាព ថែមទាំងត្រូវប្រឈមនឹងការបាត់បង់ការងារ ប្រាក់ចំណូលក្នុងគ្រួសារធ្លាក់ចុះ ដែលទាំងនេះអាចជាកត្តាហានិភ័យជម្រុញឱ្យមានអំពើហិង្សាក្នុងគ្រួសារកើនឡើង។ ដោយឡែក ច្បាប់នៅកម្ពុជាមិនទាន់មានចែងច្បាស់លាស់ពីការពិនិត្យសុខភាពផ្ទៃពោះជាប្រចាំនៅឡើយ។

**អនុសញ្ញា ១៨៩ ស្តីពីការងារសមរម្យសម្រាប់កម្មករការងារតាមផ្ទះ (ឆ្នាំ២០១១)**

យើងខ្ញុំសូមសាទរចំពោះ ក្រសួងការងារ ដែលកាលពីឆ្នាំ២០១៨ បានដាក់ចេញនូវសេចក្តីប្រកាសលេខ២៣៥ ស្តីពីលក្ខខណ្ឌការងារសម្រាប់កម្មករការងារតាមផ្ទះ ហាមឃាត់នូវទាសភាពការងារ និងពលកម្មកុមារ ជម្រុញឱ្យម្ចាស់ផ្ទះផ្តល់នូវ លក្ខខណ្ឌការងារសមរម្យនិងអត្ថប្រយោជន៍ការងាររួមទាំង អាហារ ការស្នាក់នៅ សុខភាព គ្រោះថ្នាក់ការងារ ការឈប់សម្រាក តាមរយៈកិច្ចសន្យាការងារ។ តែទោះយ៉ាងណា ក៏នៅមិនទាន់មានការអនុវត្តឱ្យមានប្រសិទ្ធភាពនូវសេចក្តីប្រកាសនេះនៅឡើយ។ កម្មករការងារតាមផ្ទះដែលភាគច្រើនជាស្ត្រីនិងក្មេងស្រីនៅតែមិនទាន់ទទួលបាននូវការគោរពសិទ្ធិ ការផ្តល់នូវអត្ថប្រយោជន៍ការងារ និងការការពារ រួមទាំងការការពារមាតុភាព ការរួចផុតពីអំពើហិង្សានិងការបៀតបៀននៅឡើយ។ ព័ត៌មានស្តីពីសិទ្ធិការងារសមរម្យរបស់កម្មករធ្វើការងារ តាមផ្ទះនៅមិនទាន់មានការចែករំលែកឱ្យបានទូលំទូលាយទេ ហើយប្រពន្ធ័នៃការរាយការណ៍ដើម្បីទទួលបានកិច្ចអន្តរាគមន៍ពីភ្នាក់ងារពាក់ពន្ធ័ ក៏នៅមានកម្រិតនៅឡើយ។

**អនុសញ្ញា ១៤៤ ស្តីពីការពិគ្រោះយោបល់ត្រីភាគីរវាងរដ្ឋ និយោជក និងកម្មករនិយោជិត (ឆ្នាំ១៩៧៦)**

សមាសភាពចូលរួមពីភាគីពាក់ព័ន្ធ ក្នុងការពិគ្រោះយោបល់ត្រីភាគី តួយ៉ាងក្នុងគណៈកម្មការក្រុមប្រឹក្សាការងារជាដើម នៅមិនទាន់មានតុល្យភាពទាំងចំនួន និងអំណាច ដែលធ្វើឱ្យយន្តការបោះឆ្នោតរកសម្លេងគាំទ្រពីភាគីពាក់ព័ន្ធ និងពិភាក្សាសម្រេចលើច្បាប់នានាឬអំពីប្រាក់ឈ្នួលជាដើម មានភាពលម្អៀងនិងមិនបានឆ្លើយតបទៅនឹងតម្រូវការនិងការពារអត្ថប្រយោជន៍របស់កម្មករនិយោជិត។

ចំពោះការពិគ្រោះយោបល់ទ្វេរភាគីវិញ ក៏ពុំទាន់មានយន្តការច្បាស់លាស់និងមានតម្លាភាពដែលអាចជួយកាត់បន្ថយទំនាស់នៅឡើយដែរ។ កន្លងមក ការពិគ្រោះយោបល់ទ្វេរភាគី នៅតាមរោងចក្រកាត់ដេរសម្លៀកបំពាក់ ស្បែកជើង និងកាបូប តែងធ្វើឡើងក្នុងទម្រង់ដែលមិនទាន់សមស្រប ឬមានភាពគម្រាមគំហែងដល់កម្មករ កម្មការនី។

ជាចុងក្រោយ ស្ថាប័នយើងខ្ញុំត្រៀមខ្លួនជាស្រេចដើម្បីចូលរួមសហការជាបច្ចេកទេស និងផ្តល់នូវធាតុចូលដែលត្រូវការចាំបាច់នៅក្នុងដំណើរការនៃការផ្តល់សច្ចាប័នទៅលើអនុសញ្ញាទាំង៤ខាងលើ។

ចូលរួមគាំទ្រសេចក្តីថ្លែងការណ៍នេះដោយ៖

1. សម្ពន្ធ័សហជីពកម្ពុជា (CATU)
2. សហភាពការងារកម្ពុជា (CLC)
3. សម្ពន្ធ័សហជីពប្រជាធិបតេយ្យកម្មករកាត់ដេរកម្ពុជា (C.CAWDU)
4. សហព័ន្ធសហជីពកម្មករសំណង់ និងព្រៃឈើកម្ពុជា (BWTUC)
5. សហភាពចលនាកម្មករកម្ពុជា (CCW)
6. សហព័ន្ធសហជីពចលនាកម្មករ (CUMW)
7. សហព័ន្ធសហជីពកម្មករចំណីអាហារនិងសេវាកម្មកម្ពុជា (CFSWF)
8. សមាគមន៍ប្រជាធិបតេយ្យឯករាជ្យនៃសេដ្ឋកិច្ចក្រៅប្រពន្ធ័ (IDEA)
9. សហព័ន្ធសហជីពសេរីស្ត្រីកាត់ដេរ (CFTUWT)
10. សហព័ន្ធសហជីពដើម្បីកម្មករ (TUFW)
11. សហព័ន្ធសហជីពជាតិនៃឧស្សាហកម្មវាយនភណ្ឌកាត់ដេរកម្ពុជា (NIFTUC)
12. សហជីពសេរីកម្មករនៃព្រះរាជាណាចក្រកម្ពុជា (FTUWKC)
13. សហព័ន្ធសហជីពមិត្តភាពកម្មករ (WFUF)
14. សហព័ន្ធសហជីពឯករាជ្យ (INTUFE)
15. សហព័ន្ធសហជីពកម្មករនិយោជិតអាស៊ាន (UFATE)
16. សហជីពការងារសេវាកម្មកម្ពុជានៃក្រុមហ៊ុនសន្តិសុខសេសហ្គាដ (SSC)
17. សម្ពន្ធ័សហជីពកម្មករដើម្បីការងារ (UCL)
18. សហព័ន្ធសហជីពការងារស្ត្រីកម្ពុជា (CWLUF)
19. អង្គការយេនឌ័រ និងអភិវឌ្ឍន៍ ដើម្បីកម្ពុជា (GADC)
20. អង្គការអាក់សិនអេតកម្ពុជា (ActionAid)
21. សុខ លាំង, អ្នកស្រាវជ្រាវនិងបណ្ដុះបណ្ដាលផ្នែកសង្គមវិទ្យានិងយេនឌ័រ
22. គណៈកម្មាធិការនៃអង្គការមិនមែនរដ្ឋាភិបាលកម្ពុជា ដើម្បីអនុសញ្ញាលុបបំបាត់រាល់ទម្រង់នៃការរើសអើងគ្រប់រូបភាពលើស្ត្រី ( NGO-CEDAW)
23. ក្រុមសន្សំប្រាក់នារី (LSG)
24. បណ្តាញយេនឌ័រ និងអភិវឌ្ឍន៍ដើម្បីកម្ពុជា (GADNet)

25. អង្គការអភិវឌ្ឍន៍ស្ត្រីក្រីក្រក្នុងទីក្រុង (UPWD)
26. សមាគមអ្នកបម្រើការងារតាមផ្ទះ (ADW)
27. អង្គការភ្នាក់ងារអភិវឌ្ឍន៍ស្ត្រីកម្ពុជា (CWDA)
28. អង្គការកម្ពុជាដើម្បីសុខភាព និងអប់រំសហគមន៍ (CHEC)
29. អង្គការនារីដើម្បីសន្តិភាព (WPM)
30. អង្គការបន្ទាយស្រី (BS)
31. សមាគមចាស អាស៊ីអាគ្នេយ៍ (JASS SEA)
32. មជ្ឈមណ្ឌលអាមេរិកកាំងសម្រាប់សាមគ្គីភាពការងារអន្តរជាតិ (ACILS/SC)
33. បណ្តាញស្ត្រីអ្នកដឹកនាំវ័យក្មេង (YWLN)
34. អង្គការអាហ្វីដា (Union Aid Abroad-APHEDA)
35. អង្គការអភិវឌ្ឍន៍សម្លេងសហគមន៍ (BCV)
36. អង្គការសកម្មភាពដៃគូសម្រាប់អភិវឌ្ឍន៍ (PFDA)
37. មជ្ឈមណ្ឌលអភិវឌ្ឍន៍កុមារនិងស្ត្រីនៅកម្ពុជា (CWDCC)
38. អង្គការមជ្ឈមណ្ឌលម្លប់ព្រហ្មវិហារធម៌ (MPC)
39. អង្គការសហគមន៍អភិវឌ្ឍន៍មិត្តជនបទ (RFCD)
40. អង្គការសហប្រតិបត្តិការដើម្បីកាត់បន្ថយភាពក្រីក្រ (COFAP)
41. អង្គការសាមគ្គី (SAMAKY)
42. អង្គការសង្គ្រោះជនទុរគតនិងមនុស្សចាស់ (HOM)
43. អង្គការកែប្រែសហគមន៍ (CTO)
44. អង្គការក្លាហាន (Klahaan)
45. អង្គការឃែរកម្ពុជា (CARE)
46. គណៈកម្មាធិការដើម្បីការបោះឆ្នោតដោយសេរី និងយុត្តិធម៌នៅកម្ពុជា (ខុមហ្វ្រែល/COMFREL)
47. អង្គការមណ្ឌលធនធានស្ត្រី (WRC)